$$f(x) = \begin{cases} c(8x - 4x^3) & \text{បើ } 0 \leq x \leq 1 \\ 0 & \text{ករណីផ្សេង} \end{cases}$$

- Find $P(X > 0.5)$.

Ans.

$$\begin{aligned} P(X > 0.5) &= \int_{0.5}^{\infty} f(x)\,dx \\ &= \int_{0.5}^{1} \frac{8x - 4x^3}{3}\,dx \\ &= \frac{1}{3}\left(4x^2 - x^4\Big|_{0.5}^{1}\right) \\ &= \frac{1}{3}\left[3 - 4 \times \left(\frac{1}{2}\right)^2 + \left(\frac{1}{2}\right)^4\right] = \frac{1}{3} \times \frac{33}{16} = \frac{11}{16} \end{aligned}$$

ឧទាហរណ៍

Suppose that X is a continuous random variable whose pdf is

$$f(x) = \begin{cases} c(8x - 4x^3) & \text{បើ } 0 \leq x \leq 1 \\ 0 & \text{ករណីផ្សេង} \end{cases}$$

- Find the cdf function : $F(x)$.

Ans.

$$\int_{-\infty}^{\infty} f(x)\,dx = 1 \implies c = 1/3$$

$$F(x) = \int_{-\infty}^{x} f(t)\,dt = \begin{cases} 0 & x < 0 \\ \frac{4x^2 - x^4}{3} & 0 \leq x \leq 1 \\ 1 & x > 1 \end{cases}$$

Note that $F(0) = 0$ and $F(1) = 1$.

បំណែងចែកប្រូបាប

ភាគ១



ការពិសោធន៍ Bernoulli

- ការពិសោធន៍ជាច្រើនគឺ មានលក្ខណៈតែ២យ៉ាង នៅក្នុងធម្មជាតិ។ ជាឧទាហរណ៍ កាក់ដែលបោះកាក់ វាចេញ 'ផ្កាប់' ឬ 'ផ្ងារ' របស់ដែលផលិតអាច 'ខូច' ឬ 'មិនខូច' ការឆ្លើយតបចំពោះសំណួរមួយអាចជា 'បាទ' ឬ 'ទេ' ស៊ុតមួយបាន 'ញាស់' ឬ 'មិនញាស់' ការសម្រេចចិត្តគឺ 'បាទ' ឬ 'ទេ' ជាដើម។
- ក្នុងករណីបែបនេះ ចាត់ទុកលទ្ធផលមួយក្នុងចំណោមលទ្ធផលថា 'ជោគជ័យ' និងអ្នកផ្សេងទៀត "បរាជ័យ" ។ ឧទាហរណ៍ក្នុងការបោះកាក់មួយប្រសិនបើចេញផ្ងារត្រូវបានចាត់ទុកថាជាជោគជ័យ បន្ទាប់មកការចេញផ្កាប់ គឺជាការបរាជ័យ។

ការពិសោធន៍ Bernoulli

- រាល់ពេលដែលយើងបោះកាក់ ឬបង្វិលគ្រាប់ឡុកឡាក់ ឬធ្វើការពិសោធន៍ផ្សេងៗ យើងហៅវាថា ជាការពិសោធន៍។
- ប្រសិនបើកាក់មួយត្រូវបានបោះ ឧបមាថា4 ដង ចំនួននៃការពិសោធន៍នេះគឺ 4 ដែលមួយលើកៗមានពីរយ៉ាងពិតប្រាកដគឺជោគជ័យ ឬបរាជ័យ។
- លទ្ធផលនៃការពិសោធន៍ណាមួយគឺឯករាជ្យពីគ្នាៗ នៅក្នុងការសាកល្បងនីមួយៗ ប្រូបាប៊ីលីតេនៃភាពជោគជ័យ ឬបរាជ័យ នៅតែថេរ។ ការពិសោធន៍បែបឯករាជ្យបែបនេះដែលមានលទ្ធផលតែពីរជាធម្មតាហៅថា 'ជោគជ័យ' ឬ 'បរាជ័យ' ត្រូវបានគេហៅថា ការសាកល្បង Bernoulli ។

ការពិសោធន៍ Bernoulli

- និយមន័យ៖ការសាកល្បងនៃការពិសោធន៍ចៃដន្យត្រូវបានគេហៅថាការសាកល្បង Bernoulli ប្រសិនបើពួកគេបំពេញលក្ខខណ្ឌខាងក្រោម៖
  i. មានចំនួនកំណត់នៃការពិសោធន៍
  ii. ការពិសោធន៍ឯករាជ្យពីគ្នា
  iii. ការពិសោធន៍នីមួយៗមានលទ្ធផលពិតប្រាកដពីរ គឺ ជោគជ័យ ឬបរាជ័យ។
  iv. ប្រូបាប៊ីលីតេនៃភាពជោគជ័យនៅតែមានដូចគ្នានៅក្នុងការពិសោធន៍នីមួយៗ។

ការពិសោធន៍ Bernoulli

- ឧទាហរណ៍ទូទៅបំផុតនៃការពិសោធន៍Bernoulli គឺការបង្វិលកាក់។ ការបង្វិលកាក់នីមួយៗមានលទ្ធផលដែលអាចកើតមានតែពីរប៉ុណ្ណោះ ផ្កាប់ ឬផ្ងារ។ ប្រសិនបើយើងចាត់ទុកផ្កាប់ថាជាជោគជ័យ នោះផ្ងារនឹងក្លាយទៅជាបរាជ័យដោយស្វ័យប្រវត្តិ ហើយផ្ទុយទៅវិញក៏ពិតដែរ។
- ឧទាហរណ៍ ការបោះគ្រាប់ឡុកឡាក់ ដើម្បីទទួលបានលេខជាក់លាក់ណាមួយក៏ជាឧទាហរណ៍មួយនៃការសាកល្បងរបស់ Bernoulli ដែរ។

អថេរចៃដន្យ Bernoulli

និយមន័យ (**អថេរចៃដន្យប៊ែរនូយី**). សម្រាប់ពិសោធន៍ប៊ែរនូយីដែលលទ្ធផលមួយជាជោគជ័យ និងមួយទៀតជាបរាជ័យ យក $p,\ 0 < p < 1$ ជាប្រូបាប៊ីលីតេដែលទទួលបានជោគជ័យ។ កំណត់អថេរចៃដន្យ X ដែល

$$X = \begin{cases} 0 & \text{បើលទ្ធផលជាបរាជ័យ} \\ 1 & \text{បើលទ្ធផលជាជោគជ័យ} \end{cases}$$

នោះ X អថេរចៃដន្យប៊ែរនូយីដែលមានអនុគមន៍ម៉ាសប្រូបាប៊ីលីតេ

$$p(x) = \mathbb{P}(X = x) = \begin{cases} 1-p, & x = 0 \\ p, & x = 1 \end{cases}$$

ឬ

$$p(x) = p^x(1-p)^{1-x},\ x = 0, 1$$

និមិត្តសញ្ញា $X \sim \mathcal{B}er(p)$ មានន័យថា X អថេរចៃដន្យប៊ែរនូយីដែលមានប៉ារ៉ាម៉ែត្រ p ។

អថេរចៃដន្យ Bernoulli

□

ឧទាហរណ៍ 5.16. 1. បោះកាក់ស្មើសាច់មួយ 1 ដង។ កំណត់អថេរចៃដន្យ X_1 ដែល $X_1 = 1$ បើកាក់ចេញ H និង $X_1 = 0$ បើកាក់ចេញ T នោះ $X_1 \sim \mathcal{B}er\left(\frac{1}{2}\right)$

2. បោះគ្រាប់ឡុកឡាក់ស្មើសាច់ 1 ដង។ កំណត់អថេរចៃដន្យ X_2 ដែល $X_2 = 1$ បើគ្រាប់ឡុកឡាក់ចេញលេខធំជាង 4 និង $X_2 = 0$ ផ្សេងពីនេះ នោះ $X_2 \sim \mathcal{B}er\left(\frac{1}{3}\right)$

ឧទាហរណ៍ 5.17. សន្មតថាថ្នាក់មួយប្រលងជាប់និទ្ទេស C ឬគ្រាន់បើជាងនេះកាលពីការប្រលងលើកមុនដោយប្រូបាប៊ីលីតេ 0.75។ តាង X ជាអថេរចៃដន្យដែល $X = 1$ បើសិស្សម្នាក់ប្រលងជាប់ និង $X = 0$ បើសិស្សម្នាក់ប្រលងធ្លាក់នោះ

$$X \sim \mathcal{B}er(0.75)$$

អថេរចៃដន្យ Bernoulli

- សង្ឃឹមគណិតនិងវ៉ារ្យង់ នៃអថេរចៃដន្យ Bernoulli
  - $\mathbb{E}[X] = p$
  - $\mathbb{V}(X) = p(1-p)$

ព្រោះ

$$\mathbb{E}[X] = \sum_{x=0}^{1} xp(x) = 0 \cdot (1-p) + 1 \cdot p = p$$

$$\mathbb{E}[X^2] = \sum_{x=0}^{1} x^2 p(x) = 0^2 \cdot (1-p) + 1^2 \cdot p = p$$

$$\mathbb{V}(X) = \mathbb{E}[X^2] - (\mathbb{E}[X])^2 = p - p^2 = p(1-p)$$

ពិសោធន៍ទ្វេធា (Binomial Trial)

និយមន័យ (**ពិសោធន៍ទ្វេធា**). ពិសោធន៍ទ្វេធាជាពិសោធន៍ដែល

- ចំនួនពិសោធន៍ជាចំនួនកំណត់ n
- ពិសោធន៍នីមួយៗមានលទ្ធផលតែពីរ៖ ជោគជ័យ និងបរាជ័យ
- ពិសោធន៍នីមួយៗមិនអាស្រ័យគ្នា
- ប្រូបាប៊ីលីតេទទួលបានជោគជ័យក្នុងពិសោធន៍នីមួយៗស្មើនឹង $p, 0 < p < 1$

ការពិសោធន៍ទ្វេធា

អនុវត្តន៍ ៖ អ្នកលេងបាល់ទាត់ម្នាក់ ទាត់បាល់តម្រង់រកទីគោលដៅ ចំនួន ៧ ដងដែលមានប្រូបាប៊ីលីតេស្មើ 0.6 នៃការទទួលទាត់ចូលទី ក្នុងម្តងៗ ។ ចូរកំណត់ថាចំនួននៃការពិសោធន៍ និងប្រូបាប៊ីលីតេនៃការដែលទាត់មិនចូលទី ជាការ ពិសោធន៍ ទ្វេធាឬទេ ?

ការពិសោធន៍ទ្វេធា

អនុវត្តន៍ ៖ ឃ្លីចំនួនប្រាំមួយត្រូវបានដកចេញជាបន្តបន្ទាប់ពីថង់ដែលមាន 7 ឃ្លីក្រហមនិង 9 ខ្មៅឃ្លី ។ តើការពិសោធន៍នេះគឺជាការពិសោធន៍ទ្វេធា ដែរឬទេ នៅពេលដែលឃ្លីត្រូវបានហូតជាបន្តបន្ទាប់ពីថង់ក្នុងករណីនីមួយដូចខាងក្រោម ?

i. ហូតហើយដាក់ទៅវិញ
ii. ហូតហើយដាក់ទៅវិញ

អថេរចៃដន្យទ្វេធា

និយមន័យ (**អថេរចៃដន្យទ្វេធា**). អថេរចៃដន្យ X ដែលតាងអោយចំនួនជោគជ័យនៅក្នុង n ពិសោធន៍ ជាអថេរចៃដន្យទ្វេធាដែលមានប៉ារ៉ាម៉ែត្រ n និង p។
និមិត្តសញ្ញា $X \sim \mathcal{B}(n, p)$ មានន័យថា X ជាអថេរចៃដន្យទ្វេធាដែលមានប៉ារ៉ាម៉ែត្រ n និង p។

ឧទាហរណ៍ 1. បោះកាក់ស្មើសាច់មួយ 4 ដង និងតាង X ជាចំនួន H ដែលទទួលបាន។ វាជាពិសោធន៍ទ្វេធាព្រោះ

- ចំនួនពិសោធន៍ $n = 4$
- ពិសោធន៍នីមួយៗមានលទ្ធផលតែពីរៈ H និង T
- ពិសោធន៍នីមួយៗមិនអាស្រ័យគ្នា
- ប្រូបាប៊ីលីតេទទួលបាន H ក្នុងពិសោធន៍នីមួយៗស្មើនឹង $\frac{1}{2}$

អថេរចៃដន្យ X ដែលជាចំនួន H ទទួលបានជាអថេរចៃដន្យទ្វេធាដែលមានប៉ារ៉ាម៉ែត្រ $n = 4$ និង $p = \frac{1}{2}$ ដែលយើងប្រើនិមិត្តសញ្ញា $X \sim \mathcal{B}\left(4, \frac{1}{2}\right)$

អថេរចៃដន្យទ្វាធា

2. នៅក្នុងសំណួរពហុជ្រើសរើសដែលមាន 10 សំណួរ និងមាន 3 ចម្លើយនៅក្នុងមួយសំណួរ។ ចំពោះសំណួរនីមួយៗមានចម្លើយត្រូវតែមួយគត់។ បើសិស្សមិនបានរៀនសម្រាប់ធ្វើតេស្តហើយសិស្សជ្រើសរើសយកចម្លើយដោយចៃដន្យ។ តាង X ជាចំនួនចម្លើយដែលសិស្សនោះឆ្លើយត្រូវ។ វាជាពិសោធន៍ទ្វេធាព្រោះ

- ចំនួនពិសោធន៍ $n = 10$
- ពិសោធន៍នីមួយៗមានលទ្ធផលតែពីរ៖ ចម្លើយត្រូវ និងចម្លើយខុស
- ពិសោធន៍នីមួយៗមិនអាស្រ័យគ្នា
- ប្រូបាប៊ីលីតេទទួលបានចម្លើយត្រូវក្នុងពិសោធន៍នីមួយៗស្មើនឹង $\frac{1}{3}$

អថេរចៃដន្យ X ដែលជាចំនួនចម្លើយត្រូវទទួលបាន ជាអថេរចៃដន្យទ្វេធាដែលមានប៉ារ៉ាម៉ែត្រ $n = 10$ និង $p = \frac{1}{3}$ ដែលយើងប្រើនិមិត្តសញ្ញា $X \sim \mathcal{B}\left(10, \frac{1}{3}\right)$

អថេរចៃដន្យទ្វាធា

ការគណនាប្រូបាប៊ីលីតេ

បើ $X \sim \mathcal{B}(n, p)$ តើ $\mathbb{P}(X = x),\ x = 0, 1, 2, \ldots, n$ ស្មើនឹងប៉ុន្មាន? យើងចាប់ផ្តើមចេញពីឧទាហរណ៍បោះកាក់ស្មើសាច់ 5 ដង។ យើងចាប់អារម្មណ៍នឹងប្រូបាប៊ីលីតេដែលទទួលបាន H 3 ដង មានន័យថាយើងត្រូវទទួលបាន H 3 ដងនិង T 2 ដងគត់ទោះបីជា H 3 ដងនិង T 2 ដងនៅក្នុងលំដាប់ណាក៏បាន។ ប្រូបាប៊ីលីតេដែលទទួលបាន H 3 ដំបូងនិង T 2 ចុងក្រោយនៃការបោះកាក់គឺ

$$\begin{aligned}\mathbb{P}(HHHTT) &= \mathbb{P}(H)\mathbb{P}(H)\mathbb{P}(H)\mathbb{P}(T)\mathbb{P}(T)\\ &= \left(\frac{1}{2}\right)^3\left(\frac{1}{2}\right)^2 = 0.0313\end{aligned}$$

តាមពិតទៅមាន 10 របៀបផ្សេងគ្នាដើម្បីទទួលបាន H 3 ដងនិង T 2 ដងនៅក្នុងលំដាប់ណាក៏បានដូចខាងក្រោម

$$\begin{array}{ll} TTHHH & HTHTH \\ THTHH & HTHHT \\ THHTH & HHTTH \\ THHHT & HHTHT \\ HTTHH & HHHTT \end{array}$$

អថេរចៃដន្យទ្វាធា

ជាទូទៅ ព្រឹត្តិការណ៍ $X = x$ ជាព្រឹត្តិការណ៍ដែលទទួលបាន x ជោគជ័យ និង $n-x$ បរាជ័យនៅក្នុងចំណោម n ពិសោធន៍។ ជោគជ័យនីមួយៗកើតឡើងដោយប្រូបាប៊ីលីតេ p និងប្រូបាប៊ីលីតេបរាជ័យនីមួយៗកើតឡើងដោយប្រូបាប៊ីលីតេ $1-p$ នោះប្រូបាប៊ីលីតេដែលទទួលបាន x ជោគជ័យ និង $n-x$ បរាជ័យនៅក្នុងចំណោម n ពិសោធន៍ គឺ $p^x(1-p)^{n-x}$។ យើងដឹងថាមាន $\binom{n}{x}$ របៀបដើម្បីទទួលបាន x ជោគជ័យ និង $n-x$ បរាជ័យនៅក្នុងចំណោម n ពិសោធន៍។
ដូច្នេះ ប្រូបាប៊ីលីតេដែល $X = x$ គឺស្មើនឹង $p^x(1-p)^{n-x}$ គុណនឹងចំនួនរបៀបដែលមានជោគជ័យចំនួន x ក្នុង n ពិសោធន៍ (ដោយមិនគិតលំដាប់) ដែលឱ្យដោយ

$$\binom{n}{x} = \frac{n!}{x!(n-x)!}$$

ដែល $n! = n \cdot (n-1) \cdot (n-2) \cdots 2 \cdot 1$ និង $0! = 1$។ ដូចនេះ

$$\mathbb{P}(X = x) = \binom{n}{x} p^x(1-p)^{n-x}, \ x = 0, 1, 2, \ldots, n$$

អថេរចៃដន្យទ្វាធា

- សង្ឃឹមគណិតនិងវ៉ារ្យង់ នៃអថេរចៃដន្យទ្វេធា
  - $\mathbb{E}[X] = np$
  - $\mathbb{V}(X) = np(1-p)$

អថេរចៃដន្យទ្វាធា

ឧទាហរណ៍ . រោងចក្រឧស្សាហកម្មមួយផ្គត់ផ្គង់សារធាតុគីមីមួយប្រភេទដល់ក្រុមហ៊ុនចំនួន 10។ ប្រូបាប៊ីលីតេដែលក្រុមហ៊ុនមួយនឹងទូរសព្ទមកកុម្ម៉ង់ក្នុងថ្ងៃណាមួយស្មើនឹង 0.2 ។ ប្រូបាប៊ីលីតេនេះគឺដូចៗគ្នាចំពោះក្រុមហ៊ុនទាំង 10 ។ រកប្រូបាប៊ីលីតេដែលនៅក្នុងថ្ងៃណាមួយចំនួនក្រុមហ៊ុនដែលទូរសព្ទមកកុម្ម៉ង់

1. យ៉ាងច្រើន 3 $\longrightarrow$ $\mathbb{P}(X \le 3) = \sum_{x=0}^{3} \binom{10}{x} (0.2)^x (0.8)^{10-x} = 0.879$
2. យ៉ាងហោចណាស់ 3 $\longrightarrow$ $\mathbb{P}(X \ge 3) = 1 - \mathbb{P}(X \le 2)$

$$= 1 - \sum_{x=0}^{2} \binom{10}{x} (0.2)^x (0.8)^{10-x}$$

$$= 1 - 0.678 = 0.322$$

3. មានចំនួន 3 $\longrightarrow$ $\mathbb{P}(X = 3) = \binom{10}{3} (0.2)^3 (0.8)^{10-3} = 0.201$

អថេរចៃដន្យទ្វាធា

ឧទាហរណ៍ ៖

បើ X ជាអថេរទ្វេធា B(6,1/3) ចូរគណនា

ក. $P(X = 4)$

ខ. $P(X \le 2)$

$$P(X=2) = C(8,2)\cdot(0.4)^2\cdot(1-0.4)^{8-2} = \frac{8!}{2!\cdot 6!}\cdot(0.4)^2\cdot(0.6)^6 = 0.2$$

$$P(X \le 2) = P(X=0) + P(X=1) + P(X=2)$$

$$P(X \le 2) = \frac{64}{729} + \frac{64}{243} + \frac{240}{729} = 0.68$$

អថេរចៃដន្យទ្វាធា

សាកល្បងគិត សិស្សម្នាក់ធ្វើតេស្តសាកល្បងនូវសំណួរពហុជ្រើសរើសដែលមាន 10 សំណួរបន្ទាប់ពីមិនបានចូលរៀនអស់ពេលមួយសប្តាហ៍។ សំណួរនីមួយៗមាន 5 ជម្រើសដែលអាចឱ្យសិស្សជ្រើសរើសចម្លើយមួយដោយឱកាសស្មើៗគ្នា។ សំណួរនីមួយៗមានចម្លើយត្រូវតែមួយគត់។ តើប្រូបាប៊ីលីតេដែលសិស្សនោះប្រលងជាប់ស្មើនឹងប៉ុន្មានបើពិន្ទុប្រលងជាប់គឺឆ្លើយត្រូវយ៉ាងហោចណាស់ 60% ?

អថេរចៃដន្យទ្វាធា (លំហាត់អនុវត្តន៍)

1. ស៊ុតចំនួន 10 ត្រូវបានដកចេញជាបន្តបន្ទាប់រួចដាក់ទៅវិញពីកញ្ច្រែង ដែលមាន10% ស៊ុតខូច។ រកប្រូបាប៊ីលីតេដែលការដកនេះមានស៊ុតដែលខូចយ៉ាងហោចណាស់មួយ។
2. ល្បែងបោះកាក់មួយ បើចេញផ្កាប់អ្នកឈ្នះ2$ និងបើចេញផ្ងារអ្នកចាញ់ 1$ ។អ្នកលេងល្បែងនេះចំនួន៨ដង គណនាប្រូបាបដើម្បីឲ្យអ្នកឈ្នះបាន15$ ។
3. អ្នកលេងល្បែងមួយដោយអ្នកឈរនៅទីតាំងនឹង 0 មួយ ។ គេបោះគ្រាប់ឡុកឡាក់មួយ បើចេញលេខ1 ឬ 6 អ្នកឈានទៅស្តាំមួយជំហាន តែបើចេញលេខក្រៅពីនេះ អ្នកទៅឆ្វេងមួយជំហាន ។ គណនាប្រូបាបដើម្បីឲ្យការបោះគ្រាប់ឡុកឡាក់លើកទី៦ អ្នកវិលមករកទីតាំង 0 វិញ ។

អថេរចៃដន្យទ្វាធា (លំហាត់អនុវត្តន៍)

4. ប្រហែល11%នៃចំនួនប្រជាជនពិភពលោកគឺជាមនុស្សប្រើដៃឆ្វេង។ អេលីន ចាប់អារម្មណ៍ក្នុងការសិក្សាចំនួនមនុស្សដែលមានដៃឆ្វេងនៅក្នុងសាលារបស់គាត់។ គាត់បានជ្រើសរើសសិស្សថ្នាក់ទី 10 នៅក្នុងវិទ្យាល័យរបស់គាត់ដែលមានសិស្សចំនួន 34 នាក់។ គណនាគម្លាតស្តង់ដារនៃការសិក្សារបស់ អេលីន។
5. និស្សិតម្នាក់ឆ្លើយសំណួរខុសឬត្រូវ (True false Questions) ចំនួន២០សំណួរ ក្នុងពេលប្រលងមុខវិជ្ជាមួយដោយឧបមាថា គាត់មិន បានរៀនមុខវិជ្ជានោះទេ ហើយគឺគាត់ចេះតែជ្រើសរើសដោយចៃដន្យ ។ បើគាត់ឆ្លើយត្រូវចាប់ពី៦០% ទើបគាត់ជាប់ ។ គណនាប្រូបាបដើម្បីឲ្យគាត់ប្រលងជាប់មុខវិជ្ជានោះ ។

អថេរចៃដន្យទ្វាធា

ឧទាហរណ៍ បោះគ្រាប់ឡុកឡាក់ស្មើសាច់មួយ 480 ដង។ រកមធ្យម វ៉ារ្យង់ និងគម្លាតស្តង់ដានៃចំនួនមុខលេខ 3 ដែលចេញ។

តាង X ជាចំនួនមុខលេខ 3 ដែលចេញនោះ $X \sim \mathcal{B}(n,p)$ ដែល $n = 480, p = \frac{1}{6}$។ ដូចនេះ

$$\mathbb{E}[X] = np = 480\left(\frac{1}{6}\right) = 80$$

$$\mathbb{V}(X) = np(1-p) = 480\left(\frac{1}{6}\right)\left(\frac{5}{6}\right) = 66.67$$

$$\mathrm{SD}(X) = \sqrt{66.67} = 8.16$$

តើប្រើប្រូបាបអ្វី?

1. ប្រសិនបើទឹក 250 លីត្រត្រូវបានគេដឹងថាត្រូវបានបំពុលដោយបាក់តេរី 10^6 នោះ តើប្រូបាបបីលីតេដែលថា គំរូទឹក 1cc មិនមានបាក់តេរីទេស្មើប៉ុន្មាន?
2. សៀវភៅដែលមាន 150 ទំព័រមាន 100 ខុសអក្សរ។ រកប្រូបាបីលីតេដែលទំព័រដាក់លាក់មួយមាន
   a. គ្មានខុសអក្សរ
   b. ខុសអក្សរ ចំនួន ៥
   c. យ៉ាងហោច ខុសអក្សរ ២
   d. ខុសអក្សរ ច្រើនជាង ១

អថេរចៃដន្យព័រសុង

អថេរចៃដន្យព័រសុងជាអថេរចៃដន្យដាច់ប្រើសម្រាប់រាប់ចំនួនព្រឹត្តិការណ៍ដែលកើតឡើងដោយចៃដន្យនៅចន្លោះពេលណាមួយ ឬលំហណាមួយ។ វាខុសពីអថេរចៃដន្យទ្វេធានៅក្នុងន័យថាទ្វេធារាប់ចំនួនជោគជ័យនិងចំនួនបរាជ័យ រីឯនៅក្នុងអថេរចៃដន្យព័រសុង ចំនួនមធ្យមនៃជោគជ័យត្រូវបានផ្តល់ឱ្យនៅក្នុងឯកតាពេល ឬលំហណាមួយ។ បើតាង X ជាចំនួននៃព្រឹត្តិការណ៍នៅចន្លោះណាមួយ និងបើចំនួនមធ្យមនៃព្រឹត្តិការណ៍នៅចន្លោះណាមួយគឺ λ នោះប្រូបាប៊ីលីតេដែលមាន x ព្រឹត្តិការណ៍នៅចន្លោះណាមួយឱ្យដោយអថេរចៃដន្យព័រសុងដូចខាងក្រោម

និយមន័យ 5.12 (**អថេរចៃដន្យព័រសុង**). អថេរចៃដន្យ X ដែលអាចយកតម្លៃ $0, 1, 2, 3, \ldots$ ហៅថាអថេរចៃដន្យព័រសុងដែលមានប៉ារ៉ាម៉ែត្រ $\lambda > 0$ បើវាមានអនុគមន៍ម៉ាសប្រូបាប៊ីលីតេ

$$\mathbb{P}(X = x) = e^{-\lambda}\frac{\lambda^x}{x!}, \quad x = 0, 1, 2, 3, \ldots$$

និមិត្តសញ្ញា $X \sim \mathcal{P}(\lambda)$ មានន័យថា X ជាអថេរចៃដន្យព័រសុងដែលមានប៉ារ៉ាម៉ែត្រ $\lambda > 0$។

អថេរចៃដន្យព័រសុង

ឧទាហរណ៍ 5.26. បើមានកំហុសក្នុងការវាយអត្ថបទចំនួន 200 ដែលនៅរាយប៉ាយដោយចៃដន្យនៅក្នុងពង្រាងឯកសារ 500 ទំព័រ។ រកប្រូបាប៊ីលីតេដែលនៅក្នុងទំព័រណាមួយមានកំហុសចំនួន 3 ។

ចម្លើយ. ចំនួនកំហុសជាមធ្យមក្នុងមួយទំព័រគឺឱ្យដោយ

$$\lambda = \frac{200}{500} = 0.4$$

តាង X ជាចំនួនកំហុសក្នុងមួយទំព័រនោះ $X \sim \mathcal{P}(\lambda)$ ដែល $\lambda = 0.4$។ ដូចនេះ

$$\mathbb{P}(X=3) = e^{-0.4}\frac{(0.4)^3}{3!} = 0.0072$$

អថេរចៃដន្យព័រសុង

ឧទាហរណ៍ ផ្នែកលក់នៃក្រុមហ៊ុនមួយទទួលការហៅចូលទូរសព្ទជាមធ្យម 3 ដងក្នុងមួយម៉ោងតាមប្រព័ន្ធទូរសព្ទមិនគិតថ្លៃ។ ចំពោះមួយម៉ោងណាមួយ រកប្រូបាប៊ីលីតេដែលគេនឹងទទួលការហៅចូលទូរសព្ទ

1. យ៉ាងច្រើន 3
2. យ៉ាងហោចណាស់ 3
3. មានចំនួន 5 ឬច្រើនជាង

ចម្លើយ. តាង X ជាចំនួនហៅចូលទូរសព្ទដែលទទួលក្នុងម៉ោងណាមួយនោះ $X \sim \mathcal{P}(\lambda)$ ដែល $\lambda = 3$។ ដូចនេះ យើងបាន

$$\begin{aligned}
\mathbb{P}(X \le 3) &= \sum_{x=0}^{3} e^{-3}\frac{3^x}{x!} = 0.6472\\
\mathbb{P}(X \ge 3) &= 1 - \mathbb{P}(X \le 2)\\
&= 1 - \sum_{x=0}^{2} e^{-3}\frac{3^x}{x!}\\
&= 1 - 0.4232 = 0.5768\\
\mathbb{P}(X \ge 5) &= 1 - \mathbb{P}(X \le 4)\\
&= 1 - \sum_{x=0}^{4} e^{-3}\frac{3^x}{x!}\\
&= 1 - 0.8152 = 0.1848
\end{aligned}$$

អនុវត្តន៍

លំហាត់ 1. បើ 2% នៃអំពូលដែលផលិតដោយក្រុមហ៊ុនមួយជាអំពូលខូច។ គណនាប្រូបាប៊ីលីតេដែលក្នុងចំណោមអំពូល 200 ដែល

(a) មានអំពូលខូច 2

(b) មានអំពូលខូចច្រើនជាង 2

(c) មានអំពូលខូចយ៉ាងច្រើន 2

2. ម៉ាស៊ីនកូពីមួយកូពីចេញដោយចៃដន្យនូវក្រដាសសចំនួន 10 សន្លឹកក្នុងចំណោម 500 សន្លឹកដែលបានកូពី។ រកប្រូបាប៊ីលីតេដែលក្នុងចំណោម 300 សន្លឹកដែលបានកូពីមាន 5 សន្លឹកជាក្រដាសស។

3. នៅក្នុងពង្រាងសៀវភៅដែលមាន 400 ទំព័រមានកំហុសចំនួន 200 ដែលនៅរាយប៉ាយដោយចៃដន្យ។ បើសិនជាទំព័រមួយត្រូវបានជ្រើសរើសដោយចៃដន្យ រកប្រូបាប៊ីលីតេដែលវាមានកំហុសមួយ។

4. ចំនួនអង្គធាតុវិទ្យុសកម្មដែលបញ្ចេញដោយអាចម៍ផ្កាយត្រូវបានកត់ត្រា។ ចំនួនមធ្យមនៃអង្គធាតុត្រូវបានរកឃើញថាស្មើនឹង 3.5 ក្នុងមួយនាទី។ រកប្រូបាប៊ីលីតេដែលក្នុងមួយនាទីណាមួយ

(a) មិនមានអង្គធាតុ

(b) មានអង្គធាតុ 2

(c) យ៉ាងហោចណាស់មាន 5 អង្គធាតុ

ប្រូបាបអថេរចៃដន្យន័រម៉ាល់



1

ចំណោទដែលត្រូវការចម្លើយ!

1. នៅក្នុងការស្ទង់មតិដែលធ្វើឡើងដោយមជ្ឈមណ្ឌលជាតិសម្រាប់ស្ថិតិសុខភាព កម្ពស់មធ្យមគំរូរបស់ស្ត្រីនៅសហរដ្ឋអាមេរិក (អាយុ 20-29 ឆ្នាំ) គឺ 163.068 cm ជាមួយនឹង គម្លាតស្តង់ដា 7.366 cm។ តើចន្លោះកំពស់ណានៃស្ត្រី ដែលមាន
   a. 68% នៃកម្ពស់របស់ស្ត្រី
   b. ៩៥% នៃកម្ពស់របស់ស្ត្រី
   c. កម្ពស់ទាំងអស់ឬស្ទើរតែទាំងអស់របស់ស្ត្រី

2

ចំណោទដែលត្រូវការចម្លើយ!

2. ក្រុមហ៊ុនដឹកទំនិញមួយបានរកឃើញថារថយន្តដឹកទំនិញរបស់ខ្លួនជាមធ្យមស៊ីសាំង11.6 លីត្រក្នុងចំងាយផ្លូវ១០០ គីឡូម៉ែត្រ ជាមួយនឹងគម្លាតស្តង់ដារ 1.6លីត្រ ក្នុងការដឹកជញ្ជូនផ្លូវហាយវេ។ តើប្រូបាប៊ីលីតេស្មើប៉ុន្មានបើ
   a. ស៊ីសាំងតិចជាង១០លីត្រក្នុងចំងាយ១០០គីឡូម៉ែត្
   b. លើសពី១៣លីត្រក្នុងចំងាយ១០០ គីឡូម៉ែត្រ
   c. រវាងពី១០ទៅ១៣.២ លីត្រក្នុងចំងាយ១០០ គីឡូម៉ែត្រ

3

អំពីអថេរចៃដន្យណ័រម៉ាល់

- បំណែងចែកណ័រម៉ាល់ គឺជាគោលគំនិតសំខាន់ណាស់នៅក្នុងស្ថិតិវិទ្យា។បំណែងចែកណ័រម៉ាល់ គឺជាបំណែងចែកមានរាងកណ្តឹងដែលត្រូវបានកំណត់ដោយមធ្យម និងគម្លាតស្តង់ដាររបស់វា ហើយអាចត្រូវបានប្រើដើម្បីពិពណ៌នាអំពីបាតុភូតធម្មជាតិជាច្រើន។បំណែងចែកណ័រម៉ាល់ ស្តង់ដារគឺជាការចែកចាយធម្មតាដែលមានមធ្យម 0 និងគម្លាតស្តង់ដារនៃ 1 ហើយអាចត្រូវបានប្រើដើម្បីគណនាប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍ដែលកើតឡើង។ ការយល់ដឹងអំពីបំណែងចែកទាំងនេះ និងរបៀបប្រើប្រាស់វាអាចជួយយើងធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង និងទាញការសន្និដ្ឋានត្រឹមត្រូវពីទិន្នន័យ។

4

អំពីអថេរចៃដន្យណ័រម៉ាល់

- បំណែងចែកណ័រម៉ាល់ គឺជាបំណែងចែកប្រូបាប៊ីលីតេដែលត្រូវបានគេប្រើយ៉ាងទូលំទូលាយនៅក្នុងស្ថិតិ ហិរញ្ញវត្ថុ វិស្វកម្ម វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រធម្មជាតិ។ វាគឺជាបំណែងចែក ដែលមានខ្សែកោងរាងកណ្ដឹង ហើយត្រូវបានកំណត់ដោយមធ្យម និងគម្លាតស្តង់ដាររបស់វា។

បំណែងចែកណ័រម៉ាល់

បំណែងចែកន័រម៉ាល់ជាបំណែងចែកដែលមានសារៈសំខាន់ខ្លាំង ហើយត្រូវគេប្រើប្រាស់នៅក្នុងវិស័យស្ថិតិវិទ្យាទាំងមូល។ ក្រាហ្វរបស់វាដែលគេហៅឈ្មោះថា *ខ្សែកោងន័រម៉ាល់* មានសណ្ឋានជារាង«ជួង»



នៅឆ្នាំ១៧៣៣ Abraham DeMoivre បានបង្កើតសមីការគណិតវិទ្យារបស់ខ្សែកោងន័រម៉ាល់នេះឡើង។ វាជាមូលដ្ឋានគ្រឹះនៃការចាប់ផ្តើមនូវទ្រឹស្តីជាច្រើននៅក្នុងស្ថិតិវិទ្យា។ បំណែងចែកន័រម៉ាល់នេះក៏ត្រូវបានគេស្គាល់ថាជា *បំណែងចែកហ្គោស*(Gaussian distribution) ដើម្បីជាកិត្តិយសដល់ Karl Friedrich Gauss (១៧៧៧, ១៨៥៥)

បំណែងចែកណ័រម៉ាល់

អនុគមន៍ដង់ស៊ីតេរបស់អថេរចៃដន្យ X ដែលមានមធ្យម μ និងវ៉ារ្យង់ σ^2 ត្រូវកំណត់ដោយ

$$n(x;\mu,\sigma)=\frac{1}{\sigma\sqrt{2\pi}}e^{-\frac{1}{2\sigma^2}(x-\mu)^2};-\infty<x<+\infty$$

ដែល $\pi = 3.14159...$ និង $e = 2.71828...$ ។

ចំណាំ៖ ក្នុងករណីជាច្រើន គេតាងអថេរចៃដន្យ X ដែលមាន មធ្យម μ និងគម្លាតស្តង់ដា σ ដោយ

$$X \sim N(\mu, \sigma^2)$$

បំណែងចែកណ័រម៉ាល់

លក្ខណៈនៃបំណែងចែកណ័រម៉ាល់

- ដោយវាជាអថេរចៃដន្យជាប់ ដូច្នេះ ប្រូបាបរបស់វាត្រូវបាន គណនាតាមក្រឡាផ្ទៃក្រោមខ្សែកោង
- បំណែងចែកណ័រម៉ាល់មានរាងដូចជួង ឆ្លុះគ្នាធៀបមធ្យម
- មានតម្លៃម៉ូដតែមួយគត់
- បំណែងចែកណ័រម៉ាល់ តម្លៃ មធ្យម=មេដ្យាន=ម៉ូដ
- តម្លៃអតិបរមា នៃ $f(x)$ គឺត្រង់ $x = \mu$
- ក្រឡាផ្ទៃក្រោមខ្សែកោងនិងអ័ក្សដេកស្មើ 1



បំណែងចែកណរម៉ាល់



9

បំណែងចែកណរម៉ាល់

- បើទិន្នន័យនៃសំណុំទិន្នន័យមានទម្រង់ Normal នោះ
  - ✓ ប្រហែល 68%នៃទិន្នន័យនៅចន្លោះ $\mu - \sigma$ និង $\mu + \sigma$
  - ✓ ប្រហែល 95%នៃទិន្នន័យនៅចន្លោះ $\mu - 2\sigma$ និង $\mu + 2\sigma$
  - ✓ ប្រហែល 99.7%នៃទិន្នន័យនៅចន្លោះ $\mu - 3\sigma$ និង $\mu + 3\sigma$
- បំណែងចែក Normal មានប៉ារ៉ាម៉ែត្រចំនួនពីរ គឺ មធ្យម μ និងគម្លាតស្តង់ដា σ

10

បំណែងចែកណ័រម៉ាល់



11

បំណែងចែកណ័រម៉ាល់

- **ក្រាឡាផ្ទៃក្រោមខ្សែកោងណ័រម៉ាល់**

ខ្សែកោងរបស់បំណែងចែកប្រូបាប៊ីលីតេជាប់ណាមួយ ឬអនុគមន៍ដង់ស៊ីតេណាមួយ ត្រូវបង្កើតឡើងក្នុងរបៀបយ៉ាងណាឱ្យផ្ទៃក្រឡានៅក្រោមខ្សែកោងក្នុងចន្លោះ $x = x_1$ និង $x = x_2$ ស្មើនឹងប្រូបាប៊ីលីតេដែលអថេរចៃដន្យ X នៅក្នុងចន្លោះ $x = x_1$ និង $x = x_2$ ។ ដូច្នេះ ចំពោះខ្សែកោងន័រម៉ាល់ក្នុងរូប៤.៣

$$P(x_1 < X < x_2) = \int_{x_1}^{x_2} n(x;\mu,\sigma)\,dx = \frac{1}{\sigma\sqrt{2\pi}}\int_{x_1}^{x_2} e^{-\frac{1}{2\sigma^2}(x-\mu)^2}\,dx$$

ត្រូវតំណាងដោយតំបន់ដែលមានផ្ទៃធូតៗ។



$P(x_1 < X < x_2) =$ ផ្ទៃក្រឡានៃតំបន់ធូតៗ

បំណែងចែកណ័រម៉ាល់

ដើម្បីគណនាប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍ដែល X ស្ថិតនៅក្នុងចន្លោះមួយ គេត្រូវធ្វើអាំងតេក្រាលអនុគមន៍ដង់ស៊ីតេប្រូបាប៊ីលីតេ ដែលជាកិច្ចការស្មុគស្មាញ ហើយវារឹតតែស្មុគស្មាញទៅទៀតដោយសារអនុគមន៍នេះប្រែប្រួលអាស្រ័យលើប៉ារ៉ាម៉ែត្រចំនួនពីរ គឺ μ និង σ។ អាស្រ័យហេតុនេះ ហើយទើបគេបំប្លែងអនុគមន៍ទាំងអស់នេះទៅជាអនុគមន៍មួយដែលមានមធ្យមស្មើ០ និងវ៉ារ្យ៉ង់ស្មើ១ ដែលគេស្គាល់ថាជាបំណែងចែកន័រម៉ាល់ស្តង់ដា។ អថេរចៃដន្យថ្មី តាងដោយ Z ដែល

$$Z=\frac{x-\mu}{\sigma}$$

នៅពេលដែលអថេរចៃដន្យ X កំណត់យកតម្លៃ x ណាមួយ នោះអថេរចៃដន្យ Z មានតម្លៃ $z=\frac{x-\mu}{\sigma}$ ។

បំណែងចែកណ័រម៉ាល់

$$\begin{aligned}P(x_1<X<x_2)&=\frac{1}{\sigma\sqrt{2\pi}}\int_{x_1}^{x_2}e^{-\frac{1}{2\sigma^2}(x-\mu)^2}dx\\&=\frac{1}{\sqrt{2\pi}}\int_{z_1}^{z_2}e^{-\frac{1}{2}z^2}dz\\&=\int_{z_1}^{z_2}n(z;0,1)dz=P(z_1<Z<z_2)\end{aligned}$$



និយមន័យ

បំណែងចែកប្រូបាប៊ីលីតេនៃអថេរចៃដន្យន័រម៉ាល់ដែលមានមធ្យម០ និងវ៉ារ្យ៉ង់១ ហៅថាបំណែងចែកន័រម៉ាល់ស្តង់ដា។

តារាងបំណែងចែកន័រម៉ាល់ស្តង់ដាត្រូវបានប្រើប្រាស់ដើម្បីរកផ្ទៃក្រឡាដែលស្ថិតនៅក្រោមខ្សែកោង។ ផ្ទៃក្រឡានេះគឺជាប្រូបាប៊ីលីតេ។

បំណែងចែកណរម៉ាល់ស្តង់ដារ

- ឧទាហរណ៍៖ បើអថេរចៃដន្យ X ជាអថេរចៃដន្យណរម៉ាល់ N(45, 0.000625) ចូរបំលែងវាជាអថេរចៃដន្យណរម៉ាល់ស្តង់ដា

$$Z = (X - 45)/0.025$$

- ឧទាហរណ៍៖ បើអថេរចៃដន្យ X ជាអថេរចៃដន្យណរម៉ាល់ N(45, 0.000625) យកតម្លៃ 44.95 ទៅ 45.05 តើ Z ប្រែប្រួលក្នុងចន្លោះណា ?

$$X = 45.05,\ Z = \frac{45.05 - 45}{0.025} = 2$$
$$X = 44.95,\ Z = \frac{44.95 - 45}{0.025} = -2$$

15

បំណែងចែកណរម៉ាល់ស្តង់ដារ

អនុវត្តន៍ ប្រាក់ចំណូលប្រចាំខែរបស់បុគ្គលិកលក់កុំព្យូទ័ររបស់ក្រុមហ៊ុនមួយប្រហាក់ប្រហែលបំណែងចែកណរម៉ាល់ដែលមាន មធ្យមស្មើនឹង 75ពាន់រៀល និងមានគំលាតស្តង់ដាស្មើនឹង6ពាន់រៀល។

ក. តើប្រាក់ចំនូលប្រហែល 68%ស្ថិតនៅចន្លោះប៉ុន្មានពាន់រៀល?

ខ. តើប្រាក់ចំនូលប្រហែល 95%ស្ថិតនៅចន្លោះប៉ុន្មានពាន់រៀល?

គ. តើប្រាក់ចំនូលប្រហែល 99.73% ស្ថិតនៅចន្លោះប៉ុន្មានពាន់រៀល?

16

វិធីគណនាប្រូបាបបំណែងចែកណ័រម៉ាល់ស្តង់ដារ

- ដោយហេតុថា ការគណនាប្រូបាបនៃអថេរចៃដន្យណ័រម៉ាល់ ត្រូវបានធ្វើឡើងតាមការគណនាអាំងតេក្រាល ដែលមានការលំបាកមួយចំនួន ដូច្នេះ គេបានបង្កើតតារាងដើម្បីឲ្យអ្នក ប្រើប្រាស់យកទៅប្រើប្រាស់ក្នុងការគណនាដោយពឹងលើតារាង ឬដោយការប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្សេងៗដូចជា EXCEL

z	0.00	0.01	0.02	0.03	0.04	0.05	0.06	0.
0.0	0.5000	0.5040	0.5080	0.5120	0.5160	0.5199	0.5239	0.
0.1	0.5398	0.5438	0.5478	0.5517	0.5557	0.5596	0.5636	0.
0.2	0.5793	0.5832	0.5871	0.5910	0.5948	0.5987	0.6026	0.
0.3	0.6179	0.6217	0.6255	0.6293	0.6331	0.6368	0.6406	0.
0.4	0.6554	0.6591	0.6628	0.6664	0.6700	0.6736	0.6772	0.
0.5	0.6915	0.6950	0.6985	0.7019	0.7054	0.7088	0.7123	0.
0.6	0.7257	0.7291	0.7324	0.7357	0.7389	0.7422	0.7454	0.
0.7	0.7580	0.7611	0.7642	0.7673	0.7704	0.7734	0.7764	0.
0.8	0.7881	0.7910	0.7939	0.7967	0.7995	0.8023	0.8051	0.

វិធីគណនាប្រូបាបបំណែងចែកណ័រម៉ាល់ស្តង់ដារ



វិធីគណនាប្រូបាបបំណែងចែកណ័រម៉ាល់ស្តង់ដារ

លំហាត់អនុវត្តន៍ អថេរចៃដន្យ X ដែល $X \sim N(50,8)$ ។ គណនា

ក. $P(48 < X < 54)$ ខ. $P(52 < X < 55)$ គ. $P(|X-50| < \sqrt{8})$

ក. $P(48 < X < 54)$ យើងបំលែង $X \sim N(50,8)$ ទៅ $Z \sim N(0,1)$ ដែល $Z = \dfrac{X-\mu}{\sigma}$

ដោយ $\sigma^2 = 8 \Rightarrow \sigma = \sqrt{8}$

$$P(48 < X < 54) = P(\frac{48-50}{\sqrt{8}}, \frac{X-50}{\sqrt{8}}, \frac{54-50}{\sqrt{8}})$$
$$= P(-0.71 < Z < 1.41)$$
$$= 0.2611 + 0.4207$$
$$= 0.6818$$

19

វិធីគណនាប្រូបាបបំណែងចែកណ័រម៉ាល់ស្តង់ដារ

លំហាត់អនុវត្តន៍ អថេរចៃដន្យ X ដែល $X \sim N(50,8)$ ។ គណនា

ក. $P(48 < X < 54)$ ខ. $P(52 < X < 55)$ គ. $P(|X-50| < \sqrt{8})$

ខ. $P(52 < X < 55) = (\frac{52-50}{\sqrt{8}}, \frac{X-50}{\sqrt{8}}, \frac{55-50}{\sqrt{8}})$

$$= P(0.71 < Z < 1.77)$$
$$= 0.4616 - 0.2611$$
$$= 0.2005$$

គ. $P(|X-50| < \sqrt{8}) = (-\sqrt{8} < X - 50 < \sqrt{8})$

$$= P(-1 < \frac{X-50}{\sqrt{8}} < 1)$$
$$= P(-1 < Z < 1)$$
$$= 0.3413 + 0.3413$$
$$= 0.6826$$

20

វិធីគណនាប្រូបាបបំណែងចែកណ័រម៉ាល់ស្តង់ដារ

លំហាត់អនុវត្តន៍ សន្មត X ជាអថេរចៃដន្យន័រម៉ាល់ដែលមានមធ្យម $\mu = 300$ និងវ៉ារ្យ៉ង់ $\sigma = 50$ ។ រកប្រូបាប៊ីលីតេដែល X កំណត់យកតម្លៃធំជាង362.

ដំណោះស្រាយ

តម្លៃz ដែលត្រូវគ្នានឹង $x = 362$ គឺ

$$z = \frac{362 - 300}{50} = 1.24$$

ដូច្នេះ យើងបាន

$$P(X > 362) = P(Z > 1.24) = 1 - P(Z < 1.24)$$
$$= 1 - 0.8925 = 0.1075$$



វិធីគណនាប្រូបាបបំណែងចែកណ័រម៉ាល់ស្តង់ដារ

ឧទាហរណ៍៤.៨ គេដឹងថាអាយុកាលប្រើប្រាស់របស់អំពូលភ្លើងដែលផលិតដោយក្រុមហ៊ុនមួយមានបំណែងចែកន័រម៉ាល់ដែលមានមធ្យមស្មើ800ម៉ោង និងគម្លាតស្តង់ដាស្មើ40ម៉ោង។ រកប្រូបាប៊ីលីតេដែលអំពូលភ្លើងមួយអាចប្រើប្រាស់បានក្នុងរយៈពេលពី778ម៉ោងទៅ834ម៉ោង។

តាងអថេរ X ជាអាយុកាលប្រើប្រាស់របស់អំពូលភ្លើង(គិតជាម៉ោង) នោះអ្វីដែលយើងត្រូវរកគឺ $P(778 < X < 834)$ ។ តម្លៃ z ដែលត្រូវគ្នានឹង $x_1 = 778$ និង $x_2 = 834$ គឺ

$$z_1 = \frac{778 - 800}{40} = -0.55$$

$$z_2 = \frac{834 - 800}{40} = 0.85$$



ដូច្នេះ

$$P(778 < X < 834) = P(-0.55 < Z < 0.85)$$
$$= P(Z < 0.85) - P(Z < -0.55)$$
$$= 0.8023 - 0.2912 = 0.5111$$

វិធីគណនាប្រូបាបបំលែងចែកណ័រម៉ាល់ស្តង់ដារ

<u>លំហាត់ទី5</u>: X ជាអថេរនៃ $N(100,36)$ $P(X<a)=0.8907$ ។ គណនាតម្លៃ a ។

បើយើងបំលែង $X \sim N(100,36)$ ទៅ $Z \sim N(0,1), Z=\frac{X-\mu}{\sigma}$

យើងមាន

$$P(X<a)=0.8907, Z=\frac{X-100}{6}$$

$$P(\frac{X-100}{6}<\frac{a-100}{6})=P(Z<\frac{a-100}{\sigma})$$

$$=0.8907 \quad P(Z<1.23)=0.5+0.3907$$

តែ $P(z<1.23)=0.5+0.3907$

$$=0.8907$$

នោះ $\frac{a-100}{6}=1.23$

$$\Rightarrow a=100+7.38$$

$$=107.38$$

ដូច្នេះ $a=107.38$

STANDARD NORMAL DISTRIBUTION

Z Score Table

Z	.00	.01	.02	.03	.04	.05	.06	.07	.08	.09
-1.4	.08076	.07927	.07780	.07636	.07493	.07353	.07215	.07078	.06944	.06811
-1.3	.09680	.09510	.09342	.09176	.09012	.08851	.08691	.08534	.08379	.08226
-1.2	.11507	.11314	.11123	.10935	.10749	.10565	.10383	.10204	.10027	.09853
-1.1	.13567	.13350	.13136	.12924	.12714	.12507	.12302	.12100	.11900	.11702
-1.0	.15866	.15625	.15386	.15151	.14917	.14686	.14457	.14231	.14007	.13786
-0.9	.18406	.18141	.17879	.17619	.17361	.17106	.16853	.16602	.16354	.16109
-0.8	.21186	.20897	.20611	.20327	.20045	.19766	.19489	.19215	.18943	.18673
-0.7	.24196	.23885	.23576	.23270	.22965	.22663	.22363	.22065	.21770	.21476
-0.6	.27425	.27093	.26763	.26435	.26109	.25785	.25463	.25143	.24825	.24510
-0.5	.30854	.30503	.30153	.29806	.29460	.29116	.28774	.28434	.28096	.27760
-0.4	.34458	.34090	.33724	.33360	.32997	.32636	.32276	.31918	.31561	.31207
-0.3	.38209	.37828	.37448	.37070	.36693	.36317	.35942	.35569	.35197	.34827
-0.2	.42074	.41683	.41294	.40905	.40517	.40129	.39743	.39358	.38974	.38591
-0.1	.46017	.45620	.45224	.44828	.44433	.44038	.43644	.43251	.42858	.42465
0.0	.50000	.50399	.50798	.51197	.51595	.51994	.52392	.52790	.53188	.53586
0.1	.53983	.54380	.54776	.55172	.55567	.55962	.56356	.56749	.57142	.57535
0.2	.57926	.58317	.58706	.59095	.59483	.59871	.60257	.60642	.61026	.61409
0.3	.61791	.62172	.62552	.62930	.63307	.63683	.64058	.64431	.64803	.65173
0.4	.65542	.65910	.66276	.66640	.67003	.67364	.67724	.68082	.68439	.68793
0.5	.69146	.69497	.69847	.70194	.70540	.70884	.71226	.71566	.71904	.72240
0.6	.72575	.72907	.73237	.73565	.73891	.74215	.74537	.74857	.75175	.75490
0.7	.75804	.76115	.76424	.76730	.77035	.77337	.77637	.77935	.78230	.78524
0.8	.78814	.79103	.79389	.79673	.79955	.80234	.80511	.80785	.81057	.81327
0.9	.81594	.81859	.82121	.82381	.82639	.82894	.83147	.83398	.83646	.83891
1.0	.84134	.84375	.84614	.84849	.85083	.85314	.85543	.85769	.85993	.86214
1.1	.86433	.86650	.86864	.87076	.87286	.87493	.87698	.87900	.88100	.88298
1.2	.88493	.88686	.88877	.89065	.89251	.89435	.89617	.89796	.89973	.90147
1.3	.90320	.90490	.90658	.90824	.90988	.91149	.91309	.91466	.91621	.91774
1.4	.91924	.92073	.92220	.92364	.92507	.92647	.92785	.92922	.93056	.93189

Negative Z Score Table   Positive Z Score Table

ជំពូក ៤

ផ្នែកកោនិក

៤.១ សេចក្តីផ្តើម

ក្នុងមុខវិជ្ជាគណិតវិភាគ គេឃើញខ្សែកោងតាងឱ្យអនុគមន៍ដឺក្រេទីពីរ $f(x) = ax^2 + bx + c$ ត្រូវបានគេហៅថា “parabole” ហើយ អនុគមន៍ខ្លះ ក្រាហ្វមានមែកពីរដូចគ្នា $f(x) = \frac{ax+b}{cx+d}$ ហៅថា “hyperbole” ។ រង្វង់ដែលមានផ្ចិត $\Omega(a,b)$ និងកាំ r គឺជាសំណុំចំនុច $M(x,y)$ ដែលផ្ទៀងផ្ទាត់សមីការដឺក្រេទី២ $(x-a)^2 + (y-b)^2 = r^2$ ។ ក្រៅពីនេះ ចំពោះ «រង្វង់រាងមូលពងក្រពើ» ហៅថា «អេលីប» ។

ខ្សែកោងទាំងអស់នេះ ត្រូវបានគេសិក្សាតាំងពីបុរាណមក ដែលវាមានតួនាទីសំខាន់បម្រើក្នុងវិស័យរូបវិទ្យា (ជាពិសេស ផ្នែកតារាសាស្រ្ត) ។ ខ្សែកោងទាំងនេះ អាចត្រូវបានកំណត់ថា ជាប្រសព្វរវាងកោនពីរទល់កំពូលគ្នា ជាមួយនឹងប្លង់មួយ :



៤.១.១ សមីការកំណុំរបស់កោនិក

និយមន័យ ៤.១.

គេឱ្យ F ជាចំណុចនឹង, $\mathscr{D}$ ជាបន្ទាត់ និង e ជាចំនួនពិតវិជ្ជមានមិនសូន្យ ($F \notin \mathscr{D}$)។ ចំពោះចំណុច M មួយក្នុងប្លង់ តាង H ជាចំណោលអរតូកូណាល់របស់ចំណុច M មកលើ $\mathscr{D}$ ។ កោនិកមួយ ដែលមានកំណុំ F គឺជាសំណុំចំណុច M ទាំងឡាយណា ដែលផ្ទៀងផ្ទាត់

$$\Gamma = \left\{ M : \frac{MF}{MH} = e \right\}$$

ដែល e ហៅថា **អេសង់ទ្រីស៊ីតេ** (eccentricity) ហើយបន្ទាត់ $\mathscr{D}$ ហៅថា **ប្រាប់ទិស** (ឬ ឌីរិកទ្រីក $=$ directrix) របស់កោនិក ។ បន្ទាត់ Δ ដែលកាត់កែងនឹង $\mathscr{D}$ កាត់តាមកំណុំ F ហៅថា **អ័ក្សកំណុំ** របស់កោនិក ។ ក្នុងករណី ៖

- បើ $0 < e < 1$ នោះសំណុំ Γ ហៅថា *អេលីប* (ellipse)
- បើ $e = 1$ នោះសំណុំ Γ ហៅថា *ប៉ារាបូល* (parabola)
- បើ $e > 1$ នោះសំណុំ Γ ហៅថា *អ៊ីពែរបូល* (hyperbola)



$e = 1:\ MF = MH$



$e \neq 1:\ MF = eMH$

អេសង់ទ្រីស៊ីតេ និង កំណុំ

ទ្រឹស្តីបទ ១.១: (អេសង់ទ្រីស៊ីតេ និង កំណុំ)

តាង p ជាចម្ងាយពីកំណុំ F ទៅប្រាប់ទិស $\mathscr{D}$ ។ អាស្រ័យលើតម្លៃរបស់អេសង់ទ្រីស៊ីតេ e គេទទួលបានកោនិក ដូចខាងក្រោម៖

(i) បើ $e=1$ នោះកោនិក ជាប៉ារ៉ាបូល ដែលមានសមីការ $Y^2=2pX$ នៅក្នុងតម្រុយ $\left(S,\vec{i},\vec{j}\right)$។ S ជាចំណុចកំពូលរបស់ប៉ារ៉ាបូល។

(ii) បើ $e\neq 1$ នោះ កោនិកមានផ្ចិត Ω និងកំណុំទីពីរ F' ឆ្លុះគ្នានឹងកំណុំ F ធៀបនឹង Ω ។ សមីការរបស់វានៅក្នុងប្រព័ន្ធកូអរដោនេ $\left(\Omega,\vec{i},\vec{j}\right)$ មានទម្រង់ ៖

- បើ $e<1$ នោះសមីការកោនិក $\dfrac{X^2}{a^2}+\dfrac{Y^2}{b^2}=1$ ជា អេលីប ។
- បើ $e>1$ នោះសមីការកោនិក $\dfrac{X^2}{a^2}-\dfrac{Y^2}{b^2}=1$ ជា អ៊ីពែរបូល ។

ដូច្នេះ គេបាន៖

$$a^2=\frac{e^2p}{(1-e^2)^2}\quad \text{និង}\quad b^2=\frac{e^2p}{|1-e^2|}$$

NB: អថេរ X និង Y បានមកពីការប្តូរគោល!



តាង p ជាចម្ងាយរវាង F និងប្រាប់ទិសរបស់កោនិក។ ចំនុច M មានកូអរដោនេ (x,y) នៅក្នុងប្រព័ន្ធកូអរដោនេ $\left(F,\vec{i},\vec{j}\right)$ ។ គេបាន M ស្ថិតនៅលើកោនិកដែលមានកំណុំ F, ប្រាប់ទិស $\mathscr{D}$ និង

អេសង់ទ្រីស៊ីតេ e លុះត្រាតែ ៖

$$\begin{aligned}
\frac{MF}{MH}=e \iff & MF^2=e^2MH^2\\
\iff & x^2+y^2=e^2(x+p)^2\\
\iff & x^2+y^2=e^2x^2+2e^2px-e^2p^2=0\\
\iff & \left(1-e^2\right)x^2+y^2-2e^2px-e^2p^2=0
\end{aligned}$$

សិក្សាករណីនីមួយៗ៖

i) បើ $e=1$ គេបាន៖

$$S\left(-\frac{p}{2},0\right) \quad \text{និង} \quad \begin{cases} X=x+\frac{p}{2}\\ Y=y\end{cases}$$

ក្នុងតម្រុយ $\left(S,\vec{i},\vec{j}\right)$: សមីការ $Y^2=2pX$ គឺជាប៉ារ៉ាបូល មានអ័ក្ស Δ និងកំពូល S ។

ii) ករណី $e\neq 1$ នោះគេបាន

$$\begin{aligned}
\left(1-e^2\right)x^2+y^2-2e^2px-e^2p^2&=0\\
\left(1-e^2\right)\left(x^2-\frac{2e^2p}{1-e^2}x\right)+y^2&=e^2p^2\\
\left(1-e^2\right)\left(x-\frac{e^2p}{1-e^2}\right)^2-\frac{e^4p^2}{1-e^2}+y^2&=e^2p^2\\
\left(1-e^2\right)\left(x-\frac{e^2p}{1-e^2}\right)^2+y^2&=\frac{e^4p^2}{1-e^2}+e^2p^2\\
\left(1-e^2\right)\left(x-\frac{e^2p}{1-e^2}\right)^2+y^2&=\frac{e^4p^2+e^2p^2-e^4p^2}{1-e^2}\\
\left(1-e^2\right)\left(x-\frac{e^2p}{1-e^2}\right)^2+y^2&=\frac{e^2p^2}{1-e^2}
\end{aligned}$$

ដូច្នេះតាង $\Omega\left(\frac{e^2p}{1-e^2},0\right)$ និង $\begin{cases} X=x-\frac{e^2p}{1-e^2}\\ Y=y\end{cases}$

ក្នុងតម្រុយ $\left(\Omega, \vec{i}, \vec{j}\right)$ គេបានសមីការ

$$\left(1-e^2\right) X^2+Y^2=\frac{e^2 p}{1-e^2}$$

ដែល

$$\frac{X^2}{\frac{e^2 p^2}{\left(1-e^2\right)^2}}+\frac{Y^2}{\frac{e^2 p^2}{1-e^2}}=1, \tag{a}$$

ដែលអាស្រ័យទៅនឹងសញ្ញារបស់ $1-e^2$ ។

- ករណី $1-e^2>0 \Leftrightarrow e<1$ គេតាង :

$$a^2=\frac{e^2 p^2}{\left(1-e^2\right)^2} \quad \text{និង} \quad b^2=\frac{e^2 p^2}{1-e^2}$$

ដូច្នេះសមីការ (a) : $\frac{X^2}{a^2}+\frac{Y^2}{b^2}=1$ គឺជាអេលីប មានផ្ចិត Ω និងអ័ក្សឆ្លុះ (ΩX) និង (ΩY) ។

- ករណី $1-e^2<0 \Leftrightarrow e>1$ គេតាង :

$$a^2=\frac{e^2 p^2}{\left(1-e^2\right)^2} \quad \text{និង} \quad b^2=-\frac{e^2 p^2}{1-e^2}$$

ដូច្នេះសមីការ (a) : $\frac{X^2}{a^2}-\frac{Y^2}{b^2}=1$ គឺជាអ៊ីពែរបូល មានផ្ចិត Ω និងអ័ក្សឆ្លុះ (ΩX) និង (ΩY) ។

៤.២ ធាតុសម្គាល់ (Characteristic elements)

៤.២.១ ប៉ារ៉ាបូល

ឧទាហរណ៍ ១២. ចូរកំណត់ធាតុសម្គាល់របស់ប៉ារ៉ាបូលខាងក្រោម៖

$$y^2-3x-4y-2=0$$

គេរកចំណុចកំពូល S របស់ប៉ារ៉ាបូលៈ

$$\begin{aligned} y^2-3x-4y-2=0 &\Leftrightarrow (y-2)^2-4-3x-2=0 \\ &\Leftrightarrow (y-2)^2=3(x+2) \end{aligned}$$

ដូច្នេះ $S(-2;2)$ និងដោយប្តូរអថេរ $\begin{cases} X=x+2 \\ Y=y-2 \end{cases}$ នោះគេបានសមីការ : $Y^2=3X$ ដែល $3=2p\Leftrightarrow p=\frac{3}{2}$ ។

ដោយ S កណ្តាល់ $[KF]$ គេបាន :

$$K=\left(x_S-\frac{p}{2},y_S\right)=\left(-\frac{11}{4},2\right)$$

និង

$$F=\left(x_S+\frac{p}{2},y_S\right)=\left(-\frac{5}{4},2\right)$$



៤.២.២ អេលីប

ទ្រឹស្តីបទ ២.១: (អេលីប)

បើគេសង់សមីការកោនិកមួយក្នុងតម្រុយ $\left(\Omega,\vec{i},\vec{j}\right)$ ក្រោមទម្រង់៖

$$\frac{X^2}{a^2}+\frac{Y^2}{b^2}=1 \quad \text{ដែល } a^2>b^2$$

នោះសមីការនេះជាសមីការ អេលីប។
បើគេតាង $c=\sqrt{a^2-b^2}$ នោះគេទទួលបានធាតុសម្គាល់ ដូចខាងក្រោម៖

$$e=\frac{c}{a}\quad ,\quad p=\frac{b^2}{c}\quad \text{និង}\quad \Omega F=c$$

សម្រាយបញ្ជាក់. គេដឹងថាសមីការដឺក្រេទី២ ក្នុងទម្រង់៖ $\frac{X^2}{a^2}+\frac{Y^2}{b^2}$ គឺជាអេលីប ។ លើសពីនេះ បើ កំណុំ F ស្ថិតនៅលើអ័ក្ស x នោះអ័ក្សសំខាន់ (major axis) របស់អេលីប ស្ថិតនៅលើអ័ក្ស x ដូច្នេះ $a^2>b^2$ ។

ដោយ $a^2=\frac{e^2p^2}{(1-e^2)^2}$ និង $b^2=\frac{e^2p^2}{1-e^2}$ ដូច្នេះ $\frac{b^2}{a^2}=1-e^2$ ។ ដូច្នេះ ៖

- $e^2=1-\frac{b^2}{a^2}=\frac{a^2-b^2}{a^2}$ ដោយតាង $c^2=a^2-b^2$ គេបាន $e^2=\frac{c^2}{a^2}$ ដែល $e=\frac{c}{a}$ ។

- $b^2=\frac{e^2p^2}{1-e^2}\Leftrightarrow p^2=\frac{b^2\left(1-e^2\right)}{e^2}=\frac{b^2\times\frac{b^2}{a^2}}{\frac{c^2}{a^2}}=\frac{b^4}{c^2}\Leftrightarrow p=\frac{b^2}{c}$

- $\Omega F=\frac{e^2p}{1-e^2}=\frac{b^2}{p}=b^2\times\frac{c}{b^2}=c$

ឧទាហរណ៍ ១៣. ចូរកំណត់ធាតុសម្គាល់របស់កោនិកខាងក្រោម៖

$$(x-2)^2+4(y+1)^2-25=0$$



សមីការកោនិកជាអេលីប មាន $a = 5$ និង $b = \frac{5}{2}$ ៖

$$c = \frac{5\sqrt{3}}{4}, \quad e = \frac{c}{a} = \frac{\sqrt{3}}{2}, \quad p = \frac{5\sqrt{3}}{6}, \quad \Omega F = c = \frac{5\sqrt{3}}{2}$$

៤.២.៣ អ៊ីពែបូល

ទ្រឹស្តីបទ ២.២: (អ៊ីពែបូល)

បើគេសង់សមីការកោនិកមួយនៅក្នុងតម្រុយ $\left(\Omega, \vec{i}, \vec{j}\right)$ ក្រោមទម្រង់៖

$$\frac{X^2}{a^2} - \frac{Y^2}{b^2} = 1$$

នោះសមីការកោនិកនេះជា អ៊ីពែបូល ។

បើគេតាង $c = \sqrt{a^2 + b^2}$ នោះគេបាន ធាតុសម្គាល់ ដូចខាងក្រោម៖

$$e = \frac{c}{a} \quad , \quad p = \frac{b^2}{c} \quad \text{et} \quad \Omega F = c$$

គេបានសមីការអាស៊ីមតូត : $Y = \frac{b}{a}X$ និង $Y = -\frac{b}{a}X$

សម្រាយបញ្ជាក់. គេដឹងថាសមីការដឺក្រេទី២ ក្រោមទម្រង់ : $\frac{X^2}{a^2} - \frac{Y^2}{b^2}$ គឺជាអ៊ីពែបូល ។
ដោយគេមាន $a^2 = \frac{e^2p^2}{(1-e^2)^2}$ និង $b^2 = \frac{e^2p^2}{e^2-1}$ ដូច្នេះ $\frac{b^2}{a^2} = e^2 - 1$ ។ គេបាន :

- $e^2 = 1 + \frac{b^2}{a^2} = \frac{a^2+b^2}{a^2}$ ដោយតាង $c^2 = a^2 + b^2$ នោះគេបាន $e^2 = \frac{c^2}{a^2}$ ដែល $e = \frac{c}{a}$ ។

- $b^2 = \frac{e^2p^2}{e^2-1} \Leftrightarrow p^2 = \frac{b^2\left(e^2-1\right)}{e^2} = \frac{b^2\times\frac{b^2}{a^2}}{\frac{c^2}{a^2}} = \frac{b^4}{c^2} \Leftrightarrow p = \frac{b^2}{c}$
- $\Omega\text{F} = \frac{e^2p}{e^2-1} = \frac{b^2}{p} = b^2 \times \frac{c}{b^2} = c$

ឧទាហរណ៍ ១៤. ចូរគណនាធាតុសម្គាល់របស់កោនិកខាងក្រោម៖

$$\frac{(x-2)^2}{16} - \frac{y^2}{9} + 1 = 0$$



គេមាន $a = 4$ និង $b = 3$ ។ ដូច្នេះ

$$c = 5, \quad e = \frac{c}{a} = \frac{5}{4}, \quad p = \frac{b^2}{c} = \frac{9}{5}, \quad \Omega F = c = 5, \quad \text{អាស៊ីមតូត}:\ \ \text{T}Y = \pm\frac{3}{4}$$

ជំពូក ៥
អថេរចៃដន្យមានរបាយប្រូបាបីលីតេរួម

(Jointly Distributed Random Variables)

Ham Karim

RUPP

TUP-BA

មាតិការ

1. របាយប្រូបាបីលីតេរួម
2. អថេរចៃដន្យមិនអាស្រ័យគ្នា

Outline

1. របាយប្រូបាប៊ីលីតេរួម
2. អថេរចៃដន្យមិនអាស្រ័យគ្នា

Joint PMF

Definition

គេឱ្យអថេរចៃដន្យដាច់ ពីរ X និង Y ។ អនុគមន៍របាយប្រូបាប៊ីលីតេរួម (joint PMF) របស់អថេរ X និង Y កំណត់ដូចខាងក្រោម៖

$$P_{XY}(x, y) = P(X = x, Y = y)$$

ចំណាំ.

- សញ្ញា , (comma) មានន័យថា “និង” ដូច្នេះ គេសរសេរ

$$\begin{aligned} P_{XY}(x, y) &= P(X = x, Y = y) \\ &= P((X = x) \text{ និង } (Y = y)) \end{aligned}$$

- $\sum_{\forall (x_i, y_j)} P_{XY}(x_i, y_j) = 1$

ម៉ាជីណាល PMF (Marginal PMF)

គេដឹងថាអនុគមន៍ PMF កំណត់បានព័ត៌មានទាំងអស់ ទាក់ទងនឹងបំណែងចែករបស់ X និង Y ។ ដូច្នេះ គេអាចរកបានអនុគមន៍ PMF របស់អថេរ X ចេញពីអនុគមន៍ PMF រួមជាមួយ Y ។

$$
\begin{aligned}
P_X(x) &= P(X = x) \\
&= \sum_{y_j} P\left(X = x, Y = y_j\right) \quad \text{ច្បាប់ប្រូបា.សរុប} \\
&= \sum_{y_j} P_{XY}\left(x, y_j\right)
\end{aligned}
$$

គេហៅ $P_X(x)$ ថា ម៉ាជីណាល PMF របស់អថេរ X ។ ដូចគ្នាដែរ គេកំណត់បាន ម៉ាជីណាល PMF របស់អថេរ Y ដោយ ៖ $P_Y(Y) = \sum_{x_i} P_{XY}\left(x_i, y\right)$

ឧទាហរណ៍. Joint PMF

គេឱ្យអថេរចៃដន្យពីរ X និង Y មាន PMF រួម :

	$Y=0$	$Y=1$	$Y=2$
$X=0$	$\frac{1}{6}$	$\frac{1}{4}$	$\frac{1}{8}$
$X=1$	$\frac{1}{8}$	$\frac{1}{6}$	$\frac{1}{6}$



(a) រក $P(X = 0, Y \leq 1)$ (b) ចូររកម៉ាជីណាល PMFs របស់អថេរ X និង Y ។

Joint cdf

Definition

គេឱ្យអថេរចៃដន្យមួយគូ (ជាអថេរដាច់ ឬ អថេរជាប់) X និង Y ។ អនុគមន៍របាយ ប្រូបាប៊ីលីតេកើន-រួម របស់អថេរ X និង Y កំណត់ដូចខាងក្រោម៖

$$F_{X,Y}(x,y) = P[X \leq x, Y \leq y]$$

Joint cdf

Definition

គេឱ្យអថេរចៃដន្យមួយគូ (ជាអថេរដាច់ ឬ អថេរជាប់) X និង Y ។ អនុគមន៍របាយ ប្រូបាបីលីតេកើន-រួម របស់អថេរ X និង Y កំណត់ដូចខាងក្រោម៖

$$\begin{aligned} F_{X,Y}(x,y) &= P[X \leq x, Y \leq y] \\ &= P[(X,Y) \text{ ស្ថិតនៅទិសនិរតីនៃចំណុច } (x,y)] \end{aligned}$$



លក្ខណៈរបស់ joint cdf

- សម្រាប់អថេរចៃដន្យមួយៈ គេបាន ម៉ាជីណាល cdf (marginal cdf)

$$F_X(x) = F_{X,Y}(x,\infty)$$

$$F_X(x) = P(X \leq x) = P(X \leq x, Y \leq \infty) = F_{X,Y}(x,\infty)$$

លក្ខណះរបស់ joint cdf

- សម្រាប់អថេរចៃដន្យមួយៈ គេបាន ម៉ាជីណាល cdf (marginal cdf)

$$F_X(x) = F_{X,Y}(x, \infty)$$

$$F_X(x) = P(X \leq x) = P(X \leq x, Y \leq \infty) = F_{X,Y}(x, \infty)$$

$$F_Y(y) = F_{X,Y}(\infty, y)$$

$$F_Y(y) = P(Y \leq y) = P(X \leq \infty, Y \leq y) = F_{X,Y}(\infty, y)$$

វ៉ាយប្រូបាប៊ីលីតេរួម

លក្ខណះរបស់ joint cdf

- សម្រាប់អថេរចៃដន្យមួយៈ គេបាន ម៉ាជីណាល cdf (marginal cdf)

$$F_X(x) = F_{X,Y}(x, \infty)$$

$$F_X(x) = P(X \leq x) = P(X \leq x, Y \leq \infty) = F_{X,Y}(x, \infty)$$

$$F_Y(y) = F_{X,Y}(\infty, y)$$

$$F_Y(y) = P(Y \leq y) = P(X \leq \infty, Y \leq y) = F_{X,Y}(\infty, y)$$

- ប្រូបាប៊ីលីតេរួម

$$P(X > x, Y > y) = 1 - F_X(x) - F_Y(y) + F_{X,Y}(x, y)$$

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

របាយប្រូបាបលីតេរួម

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

	0	1	2
P(B=k)			
P(W=k)			

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរ ដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺៈ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

	0	1	2
P(B=k)	$\frac{6}{12} \cdot \frac{5}{11} = \frac{15}{66}$		
P(W=k)			

របាយប្រូបាប៊ីលីតេរួម

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរ ដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺៈ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

	0	1	2
P(B=k)	$\frac{6}{12} \cdot \frac{5}{11} = \frac{15}{66}$	$2 \cdot \frac{6}{12} \cdot \frac{6}{11} = \frac{36}{66}$	
P(W=k)			

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរ ដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

	0	1	2
P(B=k)	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$	$2\cdot\frac{6}{12}\cdot\frac{6}{11}=\frac{36}{66}$	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$
P(W=k)			

របាយប្រូបាប៊ីលីតេរួម

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរ ដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

	0	1	2
P(B=k)	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$	$2\cdot\frac{6}{12}\cdot\frac{6}{11}=\frac{36}{66}$	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$
P(W=k)	$\frac{8}{12}\cdot\frac{7}{11}=\frac{28}{66}$		

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

	0	1	2
P(B=k)	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$	$2\cdot\frac{6}{12}\cdot\frac{6}{11}=\frac{36}{66}$	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$
P(W=k)	$\frac{8}{12}\cdot\frac{7}{11}=\frac{28}{66}$	$2\cdot\frac{4}{12}\cdot\frac{8}{11}=\frac{32}{66}$	

របាយប្រូបាប៊ីលីតេរួម

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

	0	1	2
P(B=k)	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$	$2\cdot\frac{6}{12}\cdot\frac{6}{11}=\frac{36}{66}$	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$
P(W=k)	$\frac{8}{12}\cdot\frac{7}{11}=\frac{28}{66}$	$2\cdot\frac{4}{12}\cdot\frac{8}{11}=\frac{32}{66}$	$\frac{4}{12}\cdot\frac{3}{11}=\frac{6}{66}$

ឧទាហរណ៍ : អថេរចៃដន្យដាច់ពីរ

គេទាញយកស្រោមជើងពីរដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតូមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា. របស់ B និង W កំណត់ដោយ :

	0	1	2
P(B=k)	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$	$2\cdot\frac{6}{12}\cdot\frac{6}{11}=\frac{36}{66}$	$\frac{6}{12}\cdot\frac{5}{11}=\frac{15}{66}$
P(W=k)	$\frac{8}{12}\cdot\frac{7}{11}=\frac{28}{66}$	$2\cdot\frac{4}{12}\cdot\frac{8}{11}=\frac{32}{66}$	$\frac{4}{12}\cdot\frac{3}{11}=\frac{6}{66}$

ចំណាំ. $P(B=k)=\dfrac{\binom{6}{k}\binom{6}{2-k}}{\binom{12}{2}}$ ហើយ $P(W=k)=\dfrac{\binom{4}{k}\binom{8}{2-k}}{\binom{12}{2}}$

គេទាញយកស្រោមជើងពីរដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតូមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា.រួម កំណត់ដោយ : $p_{B,W}(b,w)=P(B=b,W=w)$

		W: 0	1	2	
	0				
B	1				
	2				

$$P(B=b,W=w)=\left\{\vphantom{\begin{matrix}a\\b\\c\\d\end{matrix}}\right.$$

គេទាញយកស្រោមជើងពីរដោយចៃដន្យ ដោយមិនដាក់ទៅវិញ ចេញពីថតតុមួយ ដែលមានស្រោមជើងចំនួនដប់ពីរពណ៌ គឺ៖ ខ្មៅចំនួន 6 , សចំនួន 4 និង ស្វាយចំនួន 2 ។
តាង B ជាចំនួនស្រោមជើងពណ៌ខ្មៅ ហើយ W ជាចំនួនស្រោមជើងពណ៌ស។

ដូច្នេះ របាយប្រូបា.រួម កំណត់ដោយ : $p_{B,W}(b,w) = P(B=b, W=w)$

W

		0	1	2	
